ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១០-២០៦ ប្រ.ក

# ប្រ កា ស

## ស្តីពី

## ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម របស់បុគ្គលរាយការណ៍ ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា

---

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងជា ប្រធានក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនាឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៩៥ អនក្រ/តត ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាប្រធានក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- តាមសំណើរបស់លេខាធិការដ្ឋានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- យោងតាមស្មារតីនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍កម្ពុជា លើកទី៩ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០

## ស ម្រេ ច

### ប្រការ ១.- ដែនកំណត់

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យថា "បុគ្គលរាយការណ៍" សំដៅដល់គ្រឹះស្ថាន និងវិជ្ជាជីវៈដូចខាងក្រោម ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា និងត្រូវបានហៅថា"បុគ្គលរាយការណ៍" នៅក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ៖



ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ក. គ្រឹះស្ថានមិនមែនធនាគារនិងហិរញ្ញវត្ថុ ដោយរួមបញ្ចូលក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនធានារ៉ាប់រង

ខ. មូលនិធិសោធននិងវិនិយោគ ក្រុមហ៊ុនវិនិយោគ និងក្រុមហ៊ុនគ្រប់គ្រងមូលនិធិវិនិយោគ

គ. ភ្នាក់ងារអចលនទ្រព្យ អគារ និងដីធ្លី

ឃ. ការិយាល័យប្រៃសណីយ៍ដែលធ្វើប្រតិបត្តិការទូទាត់សងប្រាក់

ង. មេធាវី សារការី គណនេយ្យករ សវនករ ទីប្រឹក្សាវិនិយោគ និងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ នៅពេលដែលអ្នកទាំងនោះត្រៀមអនុវត្ត ឬអនុវត្តជំនួសអតិថិជនរបស់ខ្លួននូវសកម្មភាពដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះ

ច. កាស៊ីណូ និងស្ថាប័នល្បែងស៊ីសងផ្សេងទៀត

ឆ. អង្គការក្រៅរដ្ឋាភិបាល និងអង្គការមូលនិធិ ដែលធ្វើសកម្មភាពអាជីវកម្ម និងមូលនិធិសប្បុរសធម៌

ជ. ក្រុមហ៊ុនអាណត្តិព្យាបាល និងក្រុមហ៊ុនផ្តល់សេវាផ្សេងៗ

ឈ. គ្រឹះស្ថាន ឬវិជ្ជាជីវៈផ្សេងទៀត កំណត់ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

**ប្រការ ២.- សកម្មភាពអាជីវកម្មរបស់បុគ្គលរាយការណ៍**

នៅពេលដែល មេធាវី សារការី គណនេយ្យករ សវនករ អ្នកផ្តល់ប្រឹក្សាវិនិយោគនិងអ្នកគ្រប់គ្រងទ្រព្យសកម្ម ត្រៀមអនុវត្ត ឬអនុវត្តជំនួសអតិថិជនរបស់ខ្លួននូវសកម្មភាពទាំងឡាយ ដូចខាងក្រោម ៖

ក. ទទួលទិញ និងលក់អចលនទ្រព្យ អគារ និងដីធ្លី

ខ. គ្រប់គ្រងសាច់ប្រាក់ មូលបត្រ ឬទ្រព្យសកម្មផ្សេងទៀតរបស់អតិថិជន

- គ្រប់គ្រងគណនីធនាគារ ឬគណនីមូលបត្រ
- ចូលរួមបង្កើតប្រតិបត្តិការ ឬគ្រប់គ្រងក្រុមហ៊ុន

គ. បង្កើតប្រតិបត្តិការ ឬគ្រប់គ្រងនីតិបុគ្គល ឬកិច្ចសម្របសម្រួល និងការទិញនិងលក់អង្គភាពអាជីវកម្ម

ឃ. នៅពេលដែល ក្រុមហ៊ុនអាណត្តិព្យាបាល ត្រៀមអនុវត្ត ឬអនុវត្តជំនួសអតិថិជននូវសកម្មភាពទាំងឡាយ ដូចខាងក្រោម៖

- ធ្វើសកម្មភាពជាភ្នាក់ងារបង្កើតនីតិបុគ្គលនោះ
- ធ្វើសកម្មភាព ឬរៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាពជានាយក ឬជាលេខាធិការរបស់ក្រុមហ៊ុន ឬជាភាគទុនិកនៃក្រុមហ៊ុនសហកម្មសិទ្ធិ ឬតួនាទីប្រហាក់ប្រហែលទាក់ទងជាមួយនីតិបុគ្គលផ្សេងទៀត

- ផ្តល់ទីស្នាក់ការផ្លូវការ អាសយដ្ឋាន ឬទីតាំងអាជីវកម្ម អាសយដ្ឋានទំនាក់ទំនង ឬរដ្ឋបាល សម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិ ភាគទុនិក ឬនីតិបុគ្គលដទៃទៀត ឬការសម្របសម្រួលដទៃទៀត
- ធ្វើសកម្មភាព ឬរៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាពជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនអាណត្តិព្យាបាល
- ធ្វើសកម្មភាព ឬរៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាពជាភាគទុនិក ដែលត្រូវបានតែងតាំងជំនួសឱ្យបុគ្គលដទៃ ។

## ប្រការ ៣.- គោលការណ៍ទទួលស្គាល់អតិថិជន

បុគ្គលរាយការណ៍ ត្រូវបង្កើតគោលការណ៍ និងនីតិវិធីទទួលស្គាល់អតិថិជន ហើយត្រូវមានវិធានការសមស្រប រួមមាន សាវតារហានិភ័យនៅក្នុងគោលការណ៍ និងនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ដើម្បីកំណត់ហានិភ័យផ្សេងៗ ដែលបានបង្កើតឡើងដោយប្រភេទអតិថិជននីមួយៗ ឬអតិថិជនជារូបវន្តបុគ្គលនីមួយៗ ។

## ប្រការ ៤.- ការកំណត់សាវតារហានិភ័យ

៤.១ ក្នុងការកំណត់សាវតារហានិភ័យតាមប្រភេទអតិថិជននីមួយៗ ឬតាមអតិថិជនជារូបវន្តបុគ្គលនីមួយៗ យ៉ាងហោចណាស់ បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់ទៅលើកត្តាមួយចំនួនដូចខាងក្រោម ៖

- ប្រភពដើមរបស់អតិថិជន និងទីតាំងអាជីវកម្ម
- សាវតារនិងបុគ្គលិកលក្ខណៈពិសេសរបស់អតិថិជន
- លក្ខណៈអាជីវកម្មរបស់អតិថិជន
- រចនាសម្ព័ន្ធកម្មសិទ្ធិសម្រាប់អតិថិជនជាក្រុមហ៊ុន និង
- ព័ត៌មានផ្សេងៗដែលអាចបញ្ជាក់ថា អតិថិជនមានហានិភ័យខ្ពស់។

៤.២ បន្ទាប់ពីទទួលស្គាល់អតិថិជនជាលើកដំបូង បុគ្គលរាយការណ៍ត្រូវតាមដានសកម្មភាពគណនីអតិថិជនជាប្រចាំ ដើម្បីធានាថាសកម្មភាពគណនីនេះសមស្របទៅនឹងសាវតាររបស់អតិថិជន ។ ក្នុងករណីមានភាពមិនស្របគ្នា បុគ្គលរាយការណ៍ត្រូវវាយតម្លៃឡើងវិញថា ជាអតិថិជនមានហានិភ័យខ្ពស់ ។

## ប្រការ ៥.- ការហាមឃាត់គណនីអនាមិក និងគណនីបតិដ្ឋកម្ម

បុគ្គលរាយការណ៍ដែលបើកគណនីឱ្យអតិថិជន ត្រូវធានាថា ការបើកគណនីត្រូវតែមានម្ចាស់គណនី និងត្រូវរក្សាទុកឈ្មោះគណនីគ្រប់ពេលទាំងអស់ ។ លើសពីនេះបុគ្គលរាយការណ៍ត្រូវសម្គាល់អត្តសញ្ញាណអតិថិជន ដូចមានចែងនៅក្នុង ប្រការ ៧ និង ប្រការ ៨ នៃប្រកាសនេះ ហើយត្រូវធានាថា គ្មានអតិថិជនណាម្នាក់ត្រូវបានអនុញ្ញាតឱ្យបង្កើតទំនាក់ទំនង ឬធ្វើប្រតិបត្តិការគណនីណាមួយដែលមានឈ្មោះប្រឌិត មិនត្រឹមត្រូវ ឬក្លែងក្លាយ ។

## ប្រការ ៦.- ការយកចិត្តទុកដាក់ស្គាល់អតិថិជន

៦.១ បុគ្គលរាយការណ៍ត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន និងទាមទារឱ្យមានភស្តុតាងគ្រប់គ្រាន់ព្រមទាំងកត់ត្រាទុកឱ្យបានត្រឹមត្រូវនូវអត្តសញ្ញាណ និងលក្ខណៈគតិយុត្តិរបស់បុគ្គលដែលស្នើសុំធ្វើប្រតិបត្តិការ ។ ភស្តុតាងទាំងនេះត្រូវតែជាឯកសារដែលអាចជឿជាក់បាន ។

៦.២ ការយកចិត្តទុកដាក់ស្គាល់អតិថិជនត្រូវធ្វើឡើងនៅពេល ៖

- បង្កើតទំនាក់ទំនងអាជីវកម្មជាមួយអតិថិជន ដូចជា ការបើកគណនី ការផ្តល់សេវាប្រអប់សុវត្ថិភាព ឬការចុះកិច្ចសន្យាអាជីវកម្មផ្សេងទៀត
- អនុវត្តប្រតិបត្តិការដែលកើតឡើងតែមួយដង ឬម្តងម្កាល ដែលមានទឹកប្រាក់លើសពី សែសិបលានរៀល (៤០.០០០.០០០៛) ឬដប់ពាន់ដុល្លារអាមេរិក (១០.០០០$ ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត) ការផ្ទេរតាមប្រព័ន្ធអេឡិកត្រូនិក ដែលមានទឹកប្រាក់លើសពី បួនលានរៀល (៤.០០០.០០០រៀល) ឬមួយពាន់ដុល្លារអាមេរិក (១.០០០$ ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត)
- ដកយកសាច់ប្រាក់ឈ្នះពីការលេងល្បែង ដែលមានតម្លៃលើសពី សែសិបលានរៀល (៤០.០០០.០០០៛) ឬដប់ពាន់ដុល្លារអាមេរិក (១០.០០០$ ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត)
- បុគ្គលរាយការណ៍សង្ស័យថា ជាការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឬ
- បុគ្គលរាយការណ៍សង្ស័យពីភាពមិនត្រឹមត្រូវ ឬភាពគ្រប់គ្រាន់នៃព័ត៌មានដែលបានទទួលកន្លងមក។

៦.៣ ក្នុងការអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន បុគ្គលរាយការណ៍ យ៉ាងហោចណាស់ត្រូវ ៖

- សម្គាល់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់បុគ្គលដែលអនុវត្តប្រតិបត្តិការដោយប្រើប្រាស់ប្រភពឯកសារ ទិន្នន័យ ឬព័ត៌មានដែលឯករាជ្យ នឹងអាចជឿជាក់បានស្របតាមប្រការ ៨ ឬ ៩ នៃប្រកាសនេះ
- កំណត់ថាអតិថិជនកំពុងធ្វើប្រតិបត្តិការជំនួសបុគ្គល ឬអត្តគាហកណាមួយ
- ស្វែងយល់ពីអត្តគាហក និងរចនាសម្ព័ន្ធត្រួតពិនិត្យរបស់អតិថិជន (អត្តគាហកត្រូវបានផ្តល់និយមន័យនៅក្នុងប្រការ ៩ នៃប្រកាសនេះ )
- អនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន និងពិនិត្យពិច័យជាបន្តបន្ទាប់ដើម្បីធានាថា ព័ត៌មានដែលបានទទួលត្រូវបានធ្វើបច្ចុប្បន្នកម្ម និងសមស្របជាមួយចំណេះដឹងរបស់បុគ្គលរាយការណ៍អំពីអាជីវកម្ម និងសាវតារហានិភ័យរបស់អតិថិជន និងប្រសិនបើចាំបាច់ត្រូវដឹងពីប្រភពមូលនិធិ ។

៦.៤ ការបដិសេធរបស់អតិថិជនក្នុងការផ្តល់ព័ត៌មាន និងមិនសហការក្នុងដំណើរការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់បុគ្គលរាយការណ៍អាចចាត់ទុកជាការសង្ស័យ។

៦.៥ បុគ្គលរាយការណ៍ មិនត្រូវបើកគណនី ផ្ដើមទំនាក់ទំនងអាជីវកម្ម ឬធ្វើប្រតិបត្តិការ ឬក្នុងករណីដែលទំនាក់ទំនងអាជីវកម្មមានស្រាប់ បុគ្គលរាយការណ៍ត្រូវបញ្ឈប់ទំនាក់ទំនងទាំងនោះ ប្រសិនបើ អតិថិជនមិនអនុវត្តតាមកាតព្វកិច្ចយកចិត្តទុកដាក់ស្គាល់អតិថិជន ។ ស្ថានការណ៍បែបនេះ ត្រូវកត់ត្រាក្នុងរបាយការណ៍សង្ស័យដែលត្រូវផ្ញើជូនអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។

## ប្រការ៧.- អតិថិជនជាឯកត្តបុគ្គល

៧.១ ក្នុងការបង្កើតទំនាក់ទំនងអាជីវកម្មជាមួយអតិថិជនជាឯកត្តបុគ្គល បុគ្គលរាយការណ៍ត្រូវប្រមូលព័ត៌មានដូចជាឈ្មោះ ថ្ងៃខែឆ្នាំកំណើត លេខអត្តសញ្ញាណប័ណ្ណ លេខលិខិតឆ្លងដែន លេខយោងឯកសារអត្តសញ្ញាណអាជីវកម្ម/មុខរបរ សញ្ជាតិ និងអាសយដ្ឋាន ។

៧.២ បុគ្គលរាយការណ៍ តម្រូវឱ្យឯកត្តបុគ្គលផ្ដល់ឯកសារដើម និងថតចម្លងទុកនូវឯកសារមួយ ឬច្រើនជាង ដូចខាងក្រោម ៖

- អត្តសញ្ញាណប័ណ្ណ
- លិខិតឆ្លងដែន ឬ
- ឯកសារបញ្ជាក់ពីអត្តសញ្ញាណប្រហាក់ប្រហែលផ្សេងៗទៀត ដែលចេញផ្សាយដោយអាជ្ញាធរមានសមត្ថកិច្ច ដោយមានភ្ជាប់មកជាមួយនូវរូបថតរបស់អតិថិជន ។

## ប្រការ ៨.- អតិថិជនជាក្រុមហ៊ុន

៨.១ ក្នុងការបង្កើតទំនាក់ទំនងជាមួយអតិថិជនជាក្រុមហ៊ុន បុគ្គលរាយការណ៍ ត្រូវតម្រូវឱ្យក្រុមហ៊ុន ឬអាជីវកម្ម ផ្ដល់ឯកសារដើម និងថតចម្លងទុកឯកសារដូចខាងក្រោម ៖

- អនុស្សរណៈ លក្ខន្តិកៈ វិញ្ញាបនបត្រក្រុមហ៊ុន ក្រុមហ៊ុនសហកម្មសិទ្ធិ
- ឯកសារអត្តសញ្ញាណ របស់ក្រុមប្រឹក្សាភិបាល នាយក ភាគទុនិក ដៃគូ
- សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយក
- លិខិតផ្ទេរសិទ្ធិដល់បុគ្គលណាម្នាក់ជាតំណាងឱ្យក្រុមហ៊ុនឬអាជីវកម្ម
- សិទ្ធិអំណាច ឬការអនុញ្ញាតឱ្យធ្វើអាជីវកម្ម ។

៨.២ លើសពីនេះ បុគ្គលរាយការណ៍ត្រូវស្រាវជ្រាវ ឬសាកសួរពីប្រវត្តិរបស់ក្រុមហ៊ុនឬអាជីវកម្មដើម្បីធានាថាក្រុមហ៊ុនមិនទាន់ត្រូវបាន ឬមិនស្ថិតនៅក្នុងដំណើរការជំរះបញ្ជី ឬមានបញ្ហាលំបាកអ្វីឡើយ ។

៨.៣ បុគ្គលរាយការណ៍ ត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណនៃគ្រប់ហត្ថលេខីលើគណនី ដោយយោងទៅតាមការយកចិត្តទុកដាក់ស្គាល់អតិថិជនជាឯកត្តបុគ្គល ។ ពេលផ្លាស់ប្តូរហត្ថលេខី បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់ដើម្បីធានាថាហត្ថលេខាបច្ចុប្បន្នទាំងអស់ត្រូវបានផ្ទៀងផ្ទាត់ហើយ ។

៨.៤ ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានដែលទទួលបាន បុគ្គលរាយការណ៍ត្រូវពិនិត្យមើលការចុះបញ្ជីរបស់ក្រុមហ៊ុនឬអាជីវកម្ម ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃព័ត៌មានដែលទទួលបានអំពីអត្តសញ្ញាណរបស់ក្រុមហ៊ុនឬអាជីវកម្ម និងអភិបាល ម្ចាស់ភាគទុនិក និងនាយកនៃក្រុមហ៊ុននោះ ។

៨.៥ នៅពេលដែលអតិថិជន ឬម្ចាស់គ្រប់គ្រងភាគទុនិកជាសាជីវកម្មដែលមានកាតព្វកិច្ចបើកចំហព័ត៌មាន នៅក្នុងទីផ្សារភាគហ៊ុនដែលទទួលស្គាល់នោះ អត្តសញ្ញាណរបស់ភាគទុនិកនៃសាជីវកម្មពុំចាំបាច់ត្រូវសម្គាល់ ឬផ្ទៀងផ្ទាត់ឡើយ។

៨.៦ បុគ្គលរាយការណ៍ ក៏ត្រូវដឹងពីរចនាសម្ព័ន្ធនិងកម្មសិទ្ធិរបស់អតិថិជនជាក្រុមហ៊ុន និងកំណត់ប្រភពទុនរបស់ក្រុមហ៊ុនឬអាជីវកម្ម ។ ប្រការនេះនឹងជួយឱ្យបុគ្គលរាយការណ៍រកឃើញការសង្ស័យណាមួយដែលទាក់ទងនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធឬភាពជាម្ចាស់កម្មសិទ្ធិរបស់ក្រុមហ៊ុន ឬការផ្លាស់ប្តូរសាវតារអតិថិជន និងសកម្មភាពតាមរយៈគណនីរបស់ក្រុមហ៊ុនឬអាជីវកម្ម ។

## ប្រការ ៩.~ អគ្គគាហក

បុគ្គលរាយការណ៍ ត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនឱ្យបានហ្មត់ចត់ ដូចដែលបានអនុវត្តចំពោះអតិថិជនជាឯកត្តបុគ្គលនៅពេលសង្ស័យថា មានប្រតិបត្តិការណាមួយត្រូវបានធ្វើឡើងក្នុងនាមអគ្គគាហកបន្ថែមលើអតិថិជនដែលកំពុងធ្វើប្រតិបត្តិការនោះ ។ អគ្គគាហកជាបុគ្គលដែលបានកាន់កាប់ផ្តាច់មុខ ឬត្រួតពិនិត្យអតិថិជនណាម្នាក់ ឬជាបុគ្គលត្រូវបានធ្វើប្រតិបត្តិការជំនួស ។ អគ្គគាហកក៏រាប់បញ្ចូលនូវបុគ្គលដែលកាន់កាប់ផ្តាច់មុខលើនីតិបុគ្គល ឬការរៀបចំចាត់ចែងណាមួយផងដែរ ។

## ប្រការ ១០.~ អង្គការក្រៅរដ្ឋាភិបាល និង មូលនិធិ

១០.១ បុគ្គលរាយការណ៍ ត្រូវតម្រូវឱ្យអង្គការក្រៅរដ្ឋាភិបាល ឬមូលនិធិ ដែលមានទំនាក់ទំនងអាជីវកម្មផ្តល់ឯកសារបង្កើតស្ថាប័ន ឬឯកសារប្រហាក់ប្រហែលផ្សេងទៀត ដើម្បីធានាថា អង្គការក្រៅរដ្ឋាភិបាល និងមូលនិធិនោះត្រូវបានបង្កើត និងចុះបញ្ជីបានត្រឹមត្រូវ ។

១០.២ បុគ្គលរាយការណ៍ ត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណនៃគ្រប់ហត្ថលេខីលើគណនី ដោយយោងទៅតាមការយកចិត្តទុកដាក់ស្គាល់អតិថិជនជាឯកត្តបុគ្គល ។ ពេលផ្លាស់ប្តូរហត្ថលេខី បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់ដើម្បីធានាថាហត្ថលេខាបច្ចុប្បន្នទាំងអស់ត្រូវបានផ្ទៀងផ្ទាត់ហើយ ។

១០.៣ បុគ្គលរាយការណ៍ ត្រូវស្វែងយល់អំពីការត្រួតពិនិត្យ និងការសម្រេចរបស់អង្គការក្រៅរដ្ឋាភិបាល ឬមូលនិធិ និងការប្រើប្រាស់ប្រភពមូលនិធិ។

**ប្រការ ១១.~ គណនីអាណត្តិព្យាបាល និង គណនីតំណាង**

១១.១ បុគ្គលរាយការណ៍ ត្រូវកំណត់ថាអតិថិជនកំពុងតំណាងឱ្យបុគ្គលផ្សេងទៀត ដែលជាអ្នកទទួលអាណត្តិព្យាបាល អ្នកតំណាង ឬភ្នាក់ងារ ។

១១.២ បុគ្គលរាយកាណ៍ ត្រូវចាត់វិធានការសមស្រប ដើម្បីឱ្យដឹងពីម្ចាស់កម្មសិទ្ធិ រចនាសម្ព័ន្ធគ្រប់គ្រង និងទំនាក់ទំនងក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងៗក្នុងការកាន់កាប់គណនីអាណត្តិព្យាបាល ឬគណនីតំណាង និងត្រូវប្រមូលភស្តុតាងឱ្យបានគ្រប់គ្រាន់ស្តីពីអត្តសញ្ញាណរបស់អ្នកទូទាត់ អ្នកទទួលអាណត្តិព្យាបាល ឬអ្នកតំណាងហត្ថលេខី ដែលទទួលបានការអនុញ្ញាត អ្នកគ្រប់គ្រង និងអត្ថគាហក ។

១១.៣ បុគ្គលរាយការណ៍ ត្រូវធានាថា កាតព្វកិច្ចយកចិត្តទុកដាក់ស្គាល់អតិថិជន ត្រូវបានបំពេញសម្រាប់អត្ថគាហក នៅពេលបង្កើតគណនីអាណត្តិព្យាបាល ឬគណនីតំណាង។

១១.៤ បុគ្គលរាយការណ៍ ត្រូវតម្រូវឱ្យមានការធានាជាលាយលក្ខណ៍អក្សរពី អ្នកទទួលអាណត្តិព្យាបាល ឬអ្នកតំណាងថា ភស្តុតាងស្តីពីអត្តសញ្ញាណរបស់អត្ថគាហកត្រូវបានប្រមូល កត់ត្រា និងរក្សាទុក ហើយអ្នកអាណត្តិព្យាបាល ឬអ្នកតំណាងនោះពេញចិត្តនឹងប្រភពមូលនិធិ ។ លើសពីនេះ ព័ត៌មានស្តីពីអត្តសញ្ញាណទាំងនេះចាំបាច់ត្រូវផ្តល់ឱ្យជាបន្ទាន់ តាមការស្នើសុំរបស់បុគ្គលរាយការណ៍ ។

**ប្រការ ១២.~ គណនីអតិថិជន**

បុគ្គលរាយការណ៍ ត្រូវដឹងអំពីប្រតិបត្តិការគណនីអតិថិជន តាមរយៈមេធាវី និងគណនេយ្យករ ដែលបណ្តាលឱ្យមានការបារម្ភ ហើយត្រូវរាយការណ៍ពីប្រតិបត្តិការទាំងឡាយដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ប្រសិនបើមានការសង្ស័យណាមួយកើតឡើង ។

**ប្រការ ១៣.~ ក្រុមហ៊ុនសម្បក** (Shell Companies )

បុគ្គលរាយការណ៍ មិនត្រូវបង្កើតទំនាក់ទំនង ឬធ្វើអាជីវកម្មជាមួយក្រុមហ៊ុនដែលមិនធ្វើសកម្មភាពអាជីវកម្ម ឬពុំមានរូបភាពអាជីវកម្មនៅក្នុងប្រទេស ប៉ុន្តែប្រតិបត្តិការហិរញ្ញវត្ថុអាចត្រូវបានធ្វើឡើងតាមរយៈក្រុមហ៊ុនដែលជានីតិបុគ្គលទាំងនោះ ។

**ប្រការ ១៤.- ការពឹងផ្អែកលើអន្តរការី ឬតតិយភាគី សម្រាប់ការយកចិត្តទុកដាក់ស្គាល់អតិថិជន ឬ អាជីវកម្ម**

១៤.១ បុគ្គលរាយការណ៍ ត្រូវប្រុងប្រយ័ត្ន និងធានាថា មិនធ្វេសប្រហែស និងមិនពឹងផ្អែកទាំងស្រុងលើការយកចិត្តទុកដាក់ស្គាល់អតិថិជន ដែលធ្វើឡើងដោយអន្តរការី ឬតតិយភាគី ។ ការយកចិត្តទុកដាក់ស្គាល់អតិថិជនត្រូវតែជាការទទួលខុសត្រូវចុងក្រោយរបស់បុគ្គលរាយការណ៍ ។

១៤.២ បុគ្គលរាយការណ៍ ត្រូវប្រាកដថា អន្តរការី ៖

- អនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន ដោយការសម្គាល់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់ថា ប្រភពឯកសារទិន្នន័យ ឬព័ត៌មាន មានភាពឯករាជ្យ និងអាចជឿជាក់បាន
- សម្គាល់អត្តសញ្ញាណអត្ថគាហក ហើយចំពោះអតិថិជនជាក្រុមហ៊ុនត្រូវយល់ដឹងពីភាគទុនិក និងការគ្រប់គ្រង
- យល់ពីគោលបំណង និងលក្ខណៈអាជីវកម្ម
- មានប្រព័ន្ធសម្រាប់បុគ្គលរាយការណ៍ដែលទទួលបានឯកសារ អត្តសញ្ញាណទិន្នន័យ ដោយពុំមានការពន្យារពេល
- អនុញ្ញាតឱ្យបុគ្គលរាយការណ៍ត្រួតពិនិត្យជាប្រចាំសារឡើងវិញ ដើម្បីផ្ទៀងផ្ទាត់ការយកចិត្តទុកដាក់ស្គាល់អតិថិជន និង
- ត្រូវបានធ្វើបញ្ញត្តិកម្ម និងត្រួតពិនិត្យយ៉ាងត្រឹមត្រូវដោយអាជ្ញាធរពាក់ព័ន្ធអំពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

**ប្រការ ១៥.- អតិថិជនមិនជួបផ្ទាល់មុខ**

១៥.១ បុគ្គលរាយការណ៍ ត្រូវយកចិត្តទុកដាក់ជាពិសេសក្នុងការបង្កើត និងធ្វើអាជីវកម្មមិនជួបផ្ទាល់មុខ ហើយអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនតាមរយៈការប្រាស្រ័យផ្ទាល់ ឬតាមរយៈអន្តរការី ដូចដែលបានតម្រូវដោយប្រការ ១៤ នៃប្រកាសនេះ មុននឹងបង្កើតទំនាក់ទំនងជាមួយអតិថិជនរបស់ខ្លួន ។

១៥.២ បុគ្គលរាយការណ៍ ក៏ត្រូវបានតម្រូវឱ្យអនុវត្តយន្តការតាមដាន និងរាយការណ៍ ដើម្បីសម្គាល់អត្តសញ្ញាណសក្តានុពលនៃសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

**ប្រការ ១៦.- បុគ្គលពាក់ព័ន្ធនយោបាយ**

១៦.១ ក្នុងដំណើរការអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន បុគ្គលរាយកាណ៍ត្រូវពិនិត្យមើលអតិថិជនបច្ចុប្បន្ននិងថ្មីៗ ដើម្បីឱ្យដឹងថាអតិថិជនជាបុគ្គលពាក់ព័ន្ធ ឬពុំពាក់ព័ន្ធនយោបាយ ដូចមានចែងនៅ

ក្នុងមាត្រា ៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ បុគ្គលរាយកាណ៍ត្រូវប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់ពីអតិថិជននោះ និងត្រូវស្វែងរកព័ត៌មានដែលមានជាសាធារណៈ ដើម្បីកំណត់ហានិភ័យនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

១៦.២ ខណៈដែលបុគ្គលពាក់ព័ន្ធនយោបាយត្រូវបានសម្គាល់អត្តសញ្ញាណ បុគ្គលរាយការណ៍ត្រូវចាត់វិធានការសមស្របដើម្បីកំណត់ពីប្រភពទ្រព្យសម្បត្តិ និងមូលនិធិរបស់បុគ្គលនោះ ។

១៦.៣ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់របស់បុគ្គលរាយការណ៍ត្រូវតែជាអ្នកសម្រេចក្នុងការចូលរួម ឬបន្តទំនាក់ទំនងអាជីវកម្មជាមួយបុគ្គលពាក់ព័ន្ធនយោបាយ ។

១៦.៤ បុគ្គលរាយការណ៍ ត្រូវបង្កើតសាវតារហានិភ័យនៃបុគ្គលពាក់ព័ន្ធនយោបាយម្នាក់ៗ ដោយផ្អែកលើព័ត៌មានដែលប្រមូលបានពីអតិថិជននិងការស្រាវជ្រាវឯករាជ្យ ព្រមទាំងយល់ពីលក្ខណៈនៃទំនាក់ទំនងអាជីវកម្ម និងសកម្មភាពប្រតិបត្តិការ ។ បុគ្គលរាយការណ៍ត្រូវតាមដានជាប្រចាំនូវទំនាក់ទំនង និងសកម្មភាពទប់ទល់ហានិភ័យ និងបញ្ហាដែលកើតឡើងពីដំណើរការត្រួតពិនិត្យ ត្រូវរាយការណ៍ទៅថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បើចាំបាច់ ។

## ប្រការ ១៧.- អតិថិជនមានហានិភ័យខ្ពស់ផ្សេងទៀត

១៧.១ បុគ្គលរាយការណ៍ ត្រូវលើកកម្ពស់ការយកចិត្តទុកដាក់ស្គាល់អតិថិជនចំពោះអតិថិជនមានហានិភ័យខ្ពស់ រួមទាំងអតិថិជនជាបុគ្គលពាក់ព័ន្ធនយោបាយ ដើម្បីធានាថាបុគ្គលរាយកាណ៍មិនត្រូវបានបំភាន់ដោយអ្នកសម្អាតប្រាក់និងអ្នកផ្តល់ហិរញ្ញប្បទានភេរវកម្ម ។

១៧.២ ការលើកកម្ពស់ការយកចិត្តទុកដាក់ស្គាល់អតិថិជន យ៉ាងហោចណាស់ត្រូវមាន ៖

- ព័ត៌មានលម្អិតបន្ថែមទៀតពីអតិថិជន ជាពិសេសគោលបំណងនៃប្រតិបត្តិការ និងប្រភពនៃមូលនិធិ
- ការស្រាវជ្រាវឯករាជ្យ និងរកប្រភពព័ត៌មានបន្ថែមអំពីអតិថិជន និង
- ការអនុមតិពីថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ។

## ប្រការ ១៨.- គណនីមានស្រាប់

១៨.១ បុគ្គលរាយការណ៍ ត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាថា កំណត់ត្រានៃអតិថិជនមានស្រាប់នៅតែធ្វើបច្ចុប្បន្នកម្មនិងមានភាពពាក់ព័ន្ធ ។ លើសពីនេះ បុគ្គលរាយការណ៍ត្រូវប្រមូលភស្តុតាងបន្ថែមស្តីពីអត្តសញ្ញាណអតិថិជនមានស្រាប់ប្រសិនបើចាំបាច់ ដើម្បីធានាអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនស្របតាមបទដ្ឋាន ដែលបានកំណត់ដោយប្រកាសនេះ ។

១៨.២ បុគ្គលរាយការណ៍ ត្រូវអនុវត្តការពិនិត្យឡើងវិញឱ្យបានទៀងទាត់លើកំណត់ត្រាមានស្រាប់របស់អតិថិជន ។ ការពិនិត្យឡើងវិញនេះ យ៉ាងហោចណាស់ធ្វើឡើងនៅពេល ៖

- ប្រតិបត្តិការសំខាន់ៗកើតឡើង
- មានការផ្លាស់ប្តូរសំខាន់ៗនៅក្នុងគណនីដែលមានសកម្មភាព
- មានការផ្លាស់ប្តូរបទដ្ឋាននៃការរៀបចំឯកសាររបស់អតិថិជនយ៉ាងច្រើន ឬ
- ព័ត៌មានដែលទទួលបានពីអតិថិជនពុំគ្រប់គ្រាន់ ។

១៨.៣ ប្រសិនបើគ្មានព្រឹត្តិការណ៍ដូចខាងលើកើតឡើង បុគ្គលរាយការណ៍ចាំបាច់ត្រូវពិចារណាដោយផ្អែកលើការវាយតម្លៃហានិភ័យ និងត្រូវប្រមូលព័ត៌មានបន្ថែមពីអតិថិជនមានស្រាប់ ដែលចាត់ទុកថាមានហានិភ័យ ឱ្យស្របតាមបទដ្ឋានបច្ចុប្បន្នរបស់បុគ្គលរាយការណ៍ ។

## ប្រការ ១៩.~ ការរក្សាទុកឯកសារកត់ត្រា

១៩.១ បុគ្គលរាយការណ៍ ត្រូវរក្សាទុកកំណត់ត្រា ឯកសារ និងឯកសារចម្លងទាំងអស់ដែលទាក់ទងនឹងគ្រប់រូបភាពនៃប្រតិបត្តិការឱ្យបានយ៉ាងតិចរយៈពេល ៥ ឆ្នាំ នៅក្រោយពេលធ្វើប្រតិបត្តិការ ។ គ្រប់ទិន្នន័យអត្តសញ្ញាណ កំណត់ត្រា ឯកសារលិខិតទំនាក់ទំនងអាជីវកម្ម និងឯកសារចម្លង ដែលទទួលបានក្នុងនីតិវិធីយកចិត្តទុកដាក់ស្គាល់អតិថិជនត្រូវតែរក្សាទុកឱ្យបានយ៉ាងតិច ៥ ឆ្នាំ បន្ទាប់ពីបិទគណនី ឬបន្ទាប់ពីបញ្ចប់ទំនាក់ទំនងអាជីវកម្មជាមួយអតិថិជន ។

១៩.២ ករណីដែលកំណត់ត្រាទុកជាកម្មវត្ថុនៃការស៊ើបអង្កេតជាបន្តបន្ទាប់ ឬនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ កំណត់ត្រានោះត្រូវរក្សាទុកឱ្យបានលើសពីរយៈពេលដែលបានកំណត់រហូតដល់អាជ្ញាធរដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតបញ្ជាក់ថា ឯកសារទាំងនោះលែងមានសារប្រយោជន៍ ។

## ប្រការ ២០.~ ដាននៃសវនកម្ម

២០.១ បុគ្គលរាយការណ៍ ត្រូវធានាថា រាល់ឯកសារ និងកំណត់ត្រាដែលបានរក្សាទុក បង្កើតជាដានសវនកម្មចំពោះប្រតិបត្តិការនីមួយៗ ដែលជួយភ្នាក់ងារត្រួតពិនិត្យ និងភ្នាក់ងារមានសមត្ថកិច្ចដើម្បីតាមដានមូលនិធិ ។

២០.២ កំណត់ត្រាដែលបានរក្សាទុកទាំងនោះ ត្រូវតែអាចជួយបុគ្គលរាយការណ៍ឱ្យបង្កើតប្រវត្តិនិងលក្ខណៈ និងបង្កើតប្រតិបត្តិការនីមួយៗឡើងវិញបាន ។ កំណត់ត្រាទាំងនោះ យ៉ាងហោចណាស់ត្រូវមាន ៖

- ប្រភពមូលនិធិ ដូចជាវិធីសាស្ត្រនៃការទទួល និង/ឬអ្នកផ្តើមប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច

- អត្តសញ្ញាណបុគ្គលដែលធ្វើប្រតិបត្តិការ ប្រសិនបើមិនមែនជាម្ចាស់គណនី
- ប្រភេទប្រតិបត្តិការ និង
- ការណែនាំ និងគោលដៅនៃការផ្ទេរមូលនិធិ ។

**ប្រការ ២១.~ ទម្រង់ឯកសារដែលរក្សាទុក**

បុគ្គលរាយការណ៍ ត្រូវរក្សាទុកឯកសារពាក់ព័ន្ធ ជាច្បាប់ដើម ឬថតចម្លង ឬមីក្រូហ្វីល ឬក្នុងទម្រង់អេឡិកត្រូនិកដែលមានសុវត្ថិភាព និងអាចយកមកប្រើប្រាស់នៅពេលត្រូវការដោយត្រឹមត្រូវនិងទាន់ពេលវេលា ។

**ប្រការ ២២.~ ការតាមដានបន្ត**

២២.១ បុគ្គលរាយការណ៍ ត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនជាបន្ត ចំពោះទំនាក់ទំនងជាមួយអតិថិជនទាំងអស់ ដោយប្រើប្រាស់វិធីសាស្ត្រផ្អែកតាមហានិភ័យ ។ វិធីសាស្ត្រនេះ ត្រូវធានាថាសារការហានិភ័យរបស់អតិថិជនត្រូវបានធ្វើបច្ចុប្បន្នកម្ម ។

២២.២ បុគ្គលរាយការណ៍ ត្រូវយកចិត្តទុកដាក់ជាពិសេស និងបន្តអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនសម្រាប់គ្រប់ប្រតិបត្តិការធំៗ មិនប្រក្រតី ស្មុគស្មាញ ឬគំរូនៃប្រតិបត្តិការមិនប្រក្រតីដើម្បីកំណត់ថាតើប្រតិបត្តិការទាំងនេះមានឬពុំមានគោលបំណងស្របច្បាប់ច្បាស់លាស់ ។

**ប្រការ ២៣.~ ប្រព័ន្ធព័ត៌មានគ្រប់គ្រង**

បុគ្គលរាយការណ៍ ត្រូវបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រប់គ្រាន់មួយ ដើម្បីអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់ខ្លួន សម្រាប់សម្គាល់អត្តសញ្ញាណ និងរកឱ្យឃើញនូវប្រតិបត្តិការទាំងឡាយណាដែលខ្លួនសង្ស័យ ឬមានមូលដ្ឋានសមស្របដើម្បីសង្ស័យលើប្រតិបត្តិការ ដែលជាប់ពាក់ព័ន្ធនិងផលដែលបានមកពីសកម្មភាពខុសច្បាប់ ឬអតិថិជនដែលជាប់ទាក់ទងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ប្រព័ន្ធព័ត៌មានគ្រប់គ្រងត្រូវផ្ដល់ឱ្យបុគ្គលរាយការណ៍នូវព័ត៌មានទៀងទាត់ពេលវេលា ដើម្បីអាចរកសកម្មភាពសង្ស័យ ។

**ប្រការ ២៤.~ ការយកចិត្តទុកដាក់ពិសេស**

បុគ្គលរាយការណ៍ ត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនជាប្រចាំ ចំពោះទំនាក់ទំនងអាជីវកម្ម និងប្រតិបត្តិការជាមួយឯកត្តបុគ្គល អាជីវកម្ម ក្រុមហ៊ុន និងគ្រឹះស្ថានហិរញ្ញវត្ថុ មកពីបណ្ដាប្រទេសដែលមិនបានអនុវត្តពេញលេញតាមវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលទទួលស្គាល់ជាអន្តរជាតិ ។ បុគ្គលរាយការណ៍ត្រូវសួរសំណួរបន្ថែមពីគោលបំណង ប្រវត្តិប្រតិបត្តិការ និងទំនាក់ទំនងអាជីវកម្មឱ្យបានលម្អិត ជាលាយលក្ខណ៍អក្សរ និងបញ្ជូនទៅដល់អាជ្ញាធរមានសមត្ថកិច្ច ។

## ប្រការ ២៥.- របាយការណ៍ប្រតិបត្តិការសាច់ប្រាក់

២៥.១ បុគ្គលរាយការណ៍ ត្រូវរាយការណ៍មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នូវប្រតិបត្តិការសាច់ប្រាក់ដែលស្មើ ឬលើសពី សែសិបលានរៀល (៤០.០០០.០០០៛) ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត ។

២៥.២ របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ត្រូវផ្តល់មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា កំឡុងពេល ១៤ ថ្ងៃ ក្រោយកាលបរិច្ឆេទនៃប្រតិបត្តិការ ហើយត្រូវបំពេញក្នុងទម្រង់ "របាយការណ៍ប្រតិបត្តិការសាច់ប្រាក់" ដែលបានអនុម័តដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ឬទម្រង់ដែលអនុម័តសម្រាប់ការរាយការណ៍តាមអេឡិចត្រូនិក ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវផ្តល់ឱ្យបុគ្គលរាយការណ៍នូវច្បាប់ចម្លងនៃទម្រង់របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ ។

២៥.៣ ប្រតិបត្តិការសាច់ប្រាក់ ដែលអាចរាយការណ៍បាន រួមមាន ប្រតិបត្តិការសាច់ប្រាក់ច្រើនដងរបស់អតិថិជនម្នាក់ ឬគណនីមួយដែលមានចំនួនសរុបនៃប្រតិបត្តិការរួមគ្នាក្នុងមួយថ្ងៃ ឬចំនួនសាច់ប្រាក់ដកចេញពីការឈ្នះល្បែង ដែលស្មើ ឬលើសពីសែសិបលានរៀល (៤០.០០០.០០០៛) ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត។

## ប្រការ ២៦.- របាយការណ៍ប្រតិបត្តិការសង្ស័យ

២៦.១ បុគ្គលរាយការណ៍ ត្រូវបង្កើតប្រព័ន្ធរាយការណ៍ និងបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យភ្លាមៗ មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៅពេលមានការសង្ស័យ ឬមានមូលដ្ឋានសមស្របសង្ស័យថាប្រតិបត្តិការនោះជាប់ពាក់ព័ន្ធនឹងប្រាក់បានមកពីបទល្មើស ឬអតិថិជនដែលជាប់ពាក់ព័ន្ធនឹងការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម ។ បុគ្គលរាយការណ៍ត្រូវបង្កើតសេចក្តីណែនាំផ្ទៃក្នុងផ្ទាល់ខ្លួនអំពីរបាយការណ៍ប្រតិបត្តិការសង្ស័យ ដោយផ្សារភ្ជាប់ជាមួយច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងបញ្ញត្តិដែលបានចែងនៅក្នុងប្រកាសនេះ និងសូចនាករប្រតិបត្តិការសង្ស័យដែលមានចែងនៅក្នុងសេចក្តីណែនាំចេញផ្សាយដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាផងដែរ ។

២៦.២ បុគ្គលរាយការណ៍ ត្រូវបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យ នៅពេលដែលអតិថិជនថ្មីឬអតិថិជនបច្ចុប្បន្នមិនបានបំពេញភាតព្វកិច្ចយកចិត្តទុកដាក់ស្គាល់អតិថិជនដោយគ្មានហេតុផលសមស្រប ដោយពុំគិតថាបុគ្គលរាយការណ៍ទទួលយក បដិសេធ បន្ត ឬបញ្ចប់ទំនាក់ទំនងអាជីវកម្មជាមួយអតិថិជននោះ ។

## ប្រការ ២៧.- យន្តការរាយការណ៍

២៧.១ បុគ្គលរាយការណ៍ ត្រូវតែងតាំងមន្ត្រីថ្នាក់គ្រប់គ្រងជាន់ខ្ពស់មួយរូប ធ្វើជាមន្ត្រីប្រតិបត្តិទទួលខុសត្រូវក្នុងការបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។ មន្ត្រីប្រតិបត្តិ

ដែលបានទទួលការតែងតាំង ត្រូវដើរតួនាទីជាអ្នកទំនាក់ទំនងតែម្នាក់គត់ជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។ បុគ្គលរាយការណ៍ ត្រូវធានាថា រាល់របាយការណ៍ប្រតិបត្តិការសង្ស័យដែលបានធ្វើឡើងដោយនិយោជិតត្រូវបានផ្តល់ឱ្យមន្ត្រីប្រតិបត្តិយ៉ាងសមស្រប ។

២៧.២ បុគ្គលរាយការណ៍ ត្រូវណែនាំនិយោជិតឱ្យរាយការណ៍ប្រតិបត្តិការសង្ស័យទៅមន្ត្រីប្រតិបត្តិ ទោះបីជាគេពុំដឹងច្បាស់ថាប្រតិបត្តិការនោះជាសកម្មភាពខុសច្បាប់ ឬពិតជាកើតឡើងក៏ដោយ ។

២៧.៣ នៅពេលទទួលបានរបាយការណ៍ប្រតិបត្តិការសង្ស័យ មន្ត្រីប្រតិបត្តិត្រូវវាយតម្លៃ និងកំណត់ភ្លាមៗ ពីមូលដ្ឋានសមហេតុផលក្នុងការសង្ស័យ និងត្រូវបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យនេះជាបន្ទាន់មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក្នុងរយៈពេល ២៤ ម៉ោង ប្រសិនបើមន្ត្រីប្រតិបត្តិគិតថាគ្មានមូលហេតុសមហេតុផលទេនោះ ត្រូវកត់ត្រាតែមតិរបស់ខ្លួនប៉ុណ្ណោះ ។

២៧.៤ របាយការណ៍ប្រតិបត្តិការសង្ស័យ ដែលបញ្ជូនមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដោយមន្ត្រីប្រតិបត្តិត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយប្រើប្រាស់តារាងបំពេញដែលផ្តល់ដោយអង្គភាពស៊ើប-ការណ៍ហិរញ្ញវត្ថុកម្ពុជា ហើយប្រគល់ដោយសុវត្ថិភាព ដោយផ្ទាល់ដៃ ឬតាមសំបុត្រដែលមានសុវត្ថិភាព និង តាមអេឡិចត្រូនិកជាដើម ។

២៧.៥ បុគ្គលរាយការណ៍ ត្រូវធានាថា នៅពេលរៀបចំ និងបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យនោះត្រូវរក្សាការសម្ងាត់ និងអាចដឹងព័ត៌មាននេះបានត្រឹមតែបុគ្គលិកមានសិទ្ធិប៉ុណ្ណោះ ។

២៧.៦ បុគ្គលរាយការណ៍ ត្រូវផ្តល់សិទ្ធិឱ្យមន្ត្រីប្រតិបត្តិសហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក្នុងការផ្តល់ព័ត៌មាន និងឯកសារចាំបាច់បន្ថែមទៅតាមសំណើសុំ និងឆ្លើយតបរាល់ការសាកសួរដែល ពាក់ព័ន្ធនឹងរបាយការណ៍ប្រតិបត្តិការសង្ស័យ ។

**ប្រការ ២៨.- ការហាមឃាត់ការផ្តល់ព័ត៌មាន**

២៨.១ បុគ្គលរាយការណ៍ ត្រូវធានាថា ប្រព័ន្ធរាយការណ៍ដែលបានបង្កើតសម្រាប់បញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យត្រូវបានដំណើរការជាសម្ងាត់ ។

២៨.២ បុគ្គលរាយការណ៍ ត្រូវធានាថា អតិថិជនដែលត្រូវបានរាយការណ៍នេះ មិនត្រូវបានផ្តល់ព័ត៌មាន ឬមិនបានដឹងថាមានប្រតិបត្តិការនេះទេ ។ បុគ្គលិកទាំងអស់ត្រូវយល់ដឹងអំពី មាត្រា ១៥ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលបានចែងអំពី ការហាមឃាត់បុគ្គលណាដែលបានដឹងអំពីប្រតិបត្តិការសង្ស័យ មិនត្រូវផ្តល់ព័ត៌មាន ឬរាយការណ៍ទៅបុគ្គលផ្សេង ក្រៅពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លើកលែងតែមានការអនុញ្ញាតពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។

## ប្រការ ២៩.~ បញ្ហាផ្សេងទៀត

២៩.១ បុគ្គលរាយការណ៍ត្រូវរក្សាទុកឯកសារពេញលេញស្តីពីរបាយការណ៍ប្រតិបត្តិការសង្ស័យ ដែលនិយោជិតបានផ្ញើទៅមន្ត្រីប្រតិបត្តិ និងបានផ្ញើបន្តមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។

២៩.២ បុគ្គលរាយការណ៍ ត្រូវចាត់វិធានការសមហេតុផល ដើម្បីធ្វើយ៉ាងណាឱ្យមន្ត្រីនិងនិយោជិតដែលពាក់ព័ន្ធនឹងការអនុវត្ត ឬសម្របសម្រួលប្រតិបត្តិការរបស់អតិថិជនយល់ដឹងពីនីតិវិធីរាយការណ៍ ។

## ប្រការ ៣០.~ ការរកឃើញ និង រាយការណ៍ពីហិរញ្ញប្បទានភេរវកម្ម

៣០.១ បុគ្គលរាយការណ៍ ត្រូវចាត់វិធានការចាំបាច់ ដើម្បីអនុវត្តឱ្យស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងច្បាប់និងបទប្បញ្ញត្តិស្តីពីហិរញ្ញប្បទានភេរវកម្ម ។

៣០.២ បុគ្គលរាយការណ៍ ត្រូវធានាថា ប្រព័ន្ធនិងយន្តការរាយការណ៍ប្រតិបត្តិការសង្ស័យត្រូវបានពង្រីកគ្របដណ្តប់លើការសង្ស័យពីហិរញ្ញប្បទានភេរវកម្ម ។

៣០.៣ បុគ្គលរាយការណ៍ ត្រូវរក្សាមូលដ្ឋានទិន្នន័យ ដែលមានឈ្មោះនិងព័ត៌មានលម្អិតរបស់ភេរវករដែលមានក្នុងបញ្ជីរបស់អង្គការសហប្រជាជាតិ ហើយត្រូវយកចិត្តទុកដាក់ដល់ការបញ្ចូលគ្នារវាងមូលដ្ឋានទិន្នន័យរបស់ខ្លួន និងបញ្ជីឈ្មោះបុគ្គលដែលបានសម្គាល់អត្តសញ្ញាណផ្សេងទៀត ។ ព័ត៌មាននៅក្នុងមូលដ្ឋានទិន្នន័យត្រូវធ្វើបច្ចុប្បន្នកម្ម និងមានទំនាក់ទំនងគ្នា ហើយផ្តល់លទ្ធភាពងាយស្រួលដល់និយោជិតក្នុងការប្រើប្រាស់សម្រាប់សម្គាល់អត្តសញ្ញាណប្រតិបត្តិការសង្ស័យ និងការបង្កកគណនីឬមូលនិធិ។

៣០.៤ បុគ្គលរាយការណ៍ ត្រូវពិនិត្យឈ្មោះអតិថិជនថ្មី និងអតិថិជនមានស្រាប់ជាមួយនឹងឈ្មោះដែលមាននៅក្នុងមូលដ្ឋានទិន្នន័យ ។ ប្រសិនបើមានឈ្មោះដូចគ្នា បុគ្គលរាយការណ៍ត្រូវចាត់វិធានការសមស្របដើម្បីផ្ទៀងផ្ទាត់ និងបញ្ជាក់ពីអត្តសញ្ញាណរបស់អតិថិជននោះ ។ ប្រសិនបើឈ្មោះអតិថិជន និងឈ្មោះនៅក្នុងមូលដ្ឋានទិន្នន័យជាឈ្មោះតែមួយ ហើយជាមនុស្សតែម្នាក់ បុគ្គលរាយការណ៍ត្រូវបង្កកមូលនិធិ ឬទ្រព្យសកម្មរបស់អតិថិជននោះ និងត្រូវជូនដំណឹងមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាជាបន្ទាន់ ។ នៅពេលមានការសង្ស័យថា ប្រតិបត្តិការមួយពាក់ព័ន្ធនឹងភេរវករ បុគ្គលរាយការណ៍ត្រូវរាយការណ៍ប្រតិបត្តិការសង្ស័យនោះមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។

## ប្រការ ៣១.~ ការគ្រប់គ្រងហានិភ័យ

៣១.១ ក្រុមប្រឹក្សាភិបាលរបស់បុគ្គលរាយការណ៍ ត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាពដើម្បីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលស្របតាមតម្រូវការនៃច្បាប់និងបទប្បញ្ញត្តិ ។ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឱ្យ មានប្រសិទ្ធភាព ។

៣១.២ ក្រុមប្រឹក្សាភិបាលនិងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ត្រូវដឹង និងយល់ពីវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលស្របតាមច្បាប់ បទប្បញ្ញត្តិ បទដ្ឋានតាមវិស័យនីមួយៗ និងការអនុវត្តដ៏ប្រសើរ ក៏ដូចជាសារសំខាន់នៃការបង្កើនឱ្យមានវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដើម្បីទប់ស្កាត់ការបំភាន់របស់អ្នកសម្អាតប្រាក់ និងអ្នកផ្តល់ហិរញ្ញប្បទានភេរវកម្មមកលើបុគ្គលរាយការណ៍ ។ ក្រុមប្រឹក្សាភិបាលត្រូវត្រួតពិនិត្យឱ្យបានល្អិតល្អន់លើវិធានការទូទៅប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលត្រូវអនុវត្តដោយបុគ្គលរាយការណ៍ ។

៣១.៣ ក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ត្រូវដឹងពីហានិភ័យនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មពាក់ព័ន្ធនឹងរាល់សេវាកម្ម និងផលិតផលអាជីវកម្មរបស់ខ្លួន ។

៣១.៤ ក្រុមប្រឹក្សាភិបាល ត្រូវធានាថាបុគ្គលរាយការណ៍ យ៉ាងតិចបំផុតត្រូវមានគោលការណ៍ស្តីពីនីតិវិធី និងការត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ត្រូវជួយក្រុមប្រឹក្សាភិបាលក្នុងការបង្កើតគោលការណ៍ ហើយត្រូវធានាថា គោលការណ៍នេះស្របតាមហានិភ័យដែលពាក់ព័ន្ធនឹងលក្ខណៈអាជីវកម្ម ភាពស្មុគស្មាញ និងទំហំប្រតិបត្តិការដែលអនុវត្តដោយបុគ្គលរាយការណ៍ ។

៣១.៥ ក្រុមប្រឹក្សាភិបាលត្រូវធានាថា បុគ្គលរាយការណ៍មាននីតិវិធីសម្រាប់ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រួមទាំងគោលការណ៍ទទួលស្គាល់អតិថិជន ការយកចិត្តទុកដាក់ស្គាល់អតិថិជន ការរក្សាទុកឯកសារ ការតាមដានជាប្រចាំ ការរាយការណ៍ប្រតិបត្តិការសង្ស័យ និងការប្រឆាំងហិរញ្ញប្បទានភេរវកម្ម ។

៣១.៦ ក្រុមប្រឹក្សាភិបាល ត្រូវវាយតម្លៃតាមរយៈរបាយការណ៍ប្រចាំគ្រា អំពីការអនុវត្តរបស់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់នូវគោលការណ៍ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលបានអនុម័ត ។

៣១.៧ ក្រុមប្រឹក្សាភិបាលត្រូវកំណត់សិទ្ធិ និងការទទួលខុសត្រូវ ក្នុងការអនុវត្តវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ហើយត្រូវធានាថា មានការបែងចែកភារកិច្ច រវាងការអនុវត្តគោលការណ៍ នីតិវិធី និងការត្រួតពិនិត្យ ។ ក្រុមប្រឹក្សាភិបាលត្រូវធានាឱ្យមាន ៖

- ការតែងតាំងមន្ត្រីប្រតិបត្តិម្នាក់ ដើម្បីធានាថា គោលការណ៍ នីតិវិធី និងការត្រួតពិនិត្យ ត្រូវបានអនុវត្ត និង
- ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុងលើការសិក្សា និងវាយតម្លៃការត្រួតពិនិត្យ ដើម្បីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

៣១.៨ ក្រុមប្រឹក្សាភិបាលត្រូវពិនិត្យឡើងវិញ និងវាយតម្លៃគោលការណ៍ និងនីតិវិធីស្តីពីវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលស្របនឹងការប្រែប្រួល និងវិវឌ្ឍន៍នៃផលិតផល សេវាកម្ម និងប្រព័ន្ធបច្ចេកវិទ្យា ព្រមទាំងស្របតាមនិន្នាការនៃបច្ចេកទេសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ត្រូវអនុវត្តភាពផ្លាស់ប្តូរចាំបាច់លើគោលការណ៍ និងនីតិវិធី ដោយមានការអនុមតិពីក្រុមប្រឹក្សាភិបាល ដើម្បីធានាថា គោលការណ៍ថ្មីនេះមានភាពរឹងមាំនិងសមស្រប ។

៣១.៩ ក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ត្រូវផ្តល់ការបណ្តុះបណ្តាល និងការអប់រំឱ្យបានគ្រប់គ្រាន់ដល់និយោជិតរបស់ខ្លួនស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

## ប្រការ ៣២.- សុចរិតភាពបុគ្គលិក

ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ត្រូវធានាថា បុគ្គលរាយការណ៍ បង្កើតប្រព័ន្ធវាយតម្លៃនិយោជិត ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យឱ្យបានគ្រប់គ្រាន់ចំពោះបុគ្គលទាំងថ្មីទាំងចាស់ ហើយធានាសុចរិតភាពបុគ្គលរបស់ខ្លួនទាំងថ្មីទាំងចាស់ ដោយពុំមានការសម្រុះសម្រួល ។ ប្រព័ន្ធវាយតម្លៃនិយោជិតនេះ យ៉ាងហោចណាស់ត្រូវពិនិត្យមើលព័ត៌មានរបស់បុគ្គល រួមមាន លិខិតថ្កោលទោស ប្រវត្តិការងារ និងហិរញ្ញវត្ថុរបស់បុគ្គលិកថ្មីដែលជាផ្នែកមួយនៃដំណើរការជ្រើសរើសបុគ្គលិក ។

## ប្រការ ៣៣.- មន្ត្រីប្រតិបត្តិ

៣៣.១ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ទទួលខុសត្រូវតែងតាំងមន្ត្រីប្រតិបត្តិ ជាថ្នាក់នាយកគ្រប់គ្រងជាន់ខ្ពស់ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។ គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវធានាថាមន្ត្រីប្រតិបត្តិអនុវត្តការទទួលខុសត្រូវចំពោះការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលបុគ្គលរាយការណ៍បានបង្កើតរួមមានការបណ្តុះបណ្តាលនិយោជិតនិងការរាយការណ៍ពីប្រតិបត្តិការសង្ស័យ ។

៣៣.២ នៅពេលតែងតាំង ឬផ្លាស់ប្តូរមន្ត្រីប្រតិបត្តិ បុគ្គលរាយការណ៍ត្រូវរាយការណ៍មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អំពីព័ត៌មានលម្អិតនៃមន្ត្រីប្រតិបត្តិនោះ រួមមាន ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ លេខទូរសារ អាសយដ្ឋានអ៊ីម៉ែល និងប្រវត្តិពាក់ព័ន្ធផ្សេងៗទៀត ។

៣៣.៣ បុគ្គលរាយការណ៍ ត្រូវកំណត់ និងចងក្រងឯកសារ ឱ្យបានច្បាស់លាស់ពី តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីប្រតិបត្តិ ។ តួនាទី និងការទទួលខុសត្រូវ របស់មន្ត្រីប្រតិបត្តិក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម យ៉ាងហោចណាស់ ត្រូវធានា ៖

- អនុវត្តតាមគោលការណ៍នៃវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

- អនុវត្តប្រកបដោយប្រសិទ្ធភាពនូវនីតិវិធីសមស្របស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលរួមមានគោលការណ៍ទទួលស្គាល់អតិថិជន ការរក្សាកំណត់ត្រា ការតាមដានបន្ត ការរាយការណ៍ពីប្រតិបត្តិការសង្ស័យនិងការប្រឆាំងហិរញ្ញប្បទានភេរវកម្ម
- វាយតម្លៃទៀងទាត់លើយន្តការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដើម្បីធានាថាយន្តការនោះមានលក្ខណៈគ្រប់គ្រាន់ឆ្លើយតបតាមនិន្នាការប្រែប្រួល
- បណ្តាញទំនាក់ទំនងទៅវិញទៅមកពីនិយោជិតទៅមន្ត្រីប្រតិបត្តិត្រូវបានរក្សាឱ្យមានសុវត្ថិភាព ហើយព័ត៌មានទាំងអស់ត្រូវបានរក្សាជាការសម្ងាត់
- ប្រតិបត្តិតាមកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលកម្រូវដោយច្បាប់និងបទប្បញ្ញត្តិ
- និយោជិតទាំងអស់ត្រូវដឹងពីវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រួមមានគោលការណ៍ យន្តការត្រួតពិនិត្យ និងបណ្តាញរាយការណ៍ ដើម្បីធានាពីប្រសិទ្ធភាពនៃវិធានការទាំងនោះ
- សម្គាល់អត្តសញ្ញាណហានិភ័យនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលពាក់ព័ន្ធនឹងផលិតផល ឬសេវាកម្មថ្មី ឬដែលកើតឡើងពីការប្រែប្រួលនៃប្រតិបត្តិការរបស់បុគ្គលរាយការណ៍ រួមមានការណែនាំឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មី និងដំណើរការថ្មី ។

៣៣.៤ មន្ត្រីប្រតិបត្តិ ត្រូវមានចំណេះដឹង និងជំនាញចាំបាច់ ដើម្បីអនុវត្តការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព រួមមានចំណេះដឹងពីកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលតម្រូវដោយច្បាប់និងបទប្បញ្ញត្តិ ការយល់ដឹងពីវិវឌ្ឍន៍និងបច្ចេកទេសថ្មីៗនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

## ប្រការ ៣៤.- កម្មវិធីបង្កើនការយល់ដឹងនិងការបណ្តុះបណ្តាលបុគ្គលិក

៣៤.១ បុគ្គលរាយការណ៍ ត្រូវមានកម្មវិធីបណ្តុះបណ្តាល និងបង្កើនការយល់ដឹង ស្តីពីវិធានការនិងការអនុវត្តការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មសម្រាប់និយោជិតរបស់ខ្លួន ។

៣៤.២ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ត្រូវធានាឱ្យមានបណ្តាញទំនាក់ទំនងសមស្រប ដើម្បីផ្តល់ព័ត៌មានដល់បុគ្គលិកគ្រប់ថ្នាក់ របស់បុគ្គលរាយការណ៍ ស្តីពីគោលការណ៍ និងនីតិវិធីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

៣៤.៣ និយោជិតត្រូវដឹងពីគោលការណ៍ត្រួតពិនិត្យ និងកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលបានបញ្ជាក់នៅក្នុងប្រកាស និងនៅក្នុងក្បួនខ្នាតត្រួតពិនិត្យផ្ទៃក្នុងស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ ។

៣៤.៤ ក្បួនខ្នាតត្រួតពិនិត្យផ្ទៃក្នុងនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវមានយ៉ាងហោចណាស់ ៖

- ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា
- អនុសាសន៍ ៤០ និងអនុសាសន៍ពិសេស ៩ របស់ក្រុមការងារហិរញ្ញវត្ថុ
- វិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ ដែលបានបង្កើតឡើងដើម្បីបំពេញកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

៣៤.៥ បុគ្គលរាយការណ៍ យ៉ាងហោចណាស់ត្រូវអនុវត្តតាមតម្រូវការបណ្តុះបណ្តាល ដូចខាងក្រោមសម្រាប់ និយោជិតតាមផ្នែកផ្សេងៗ ក្នុងគ្រឹះស្ថានរបស់ខ្លួន ៖

- **និយោជិតថ្មី ៖**

  ប្រវត្តិទូទៅនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តម្រូវការនិងកាតព្វកិច្ចសម្គាល់អត្តសញ្ញាណ និងរាយការណ៍ប្រតិបត្តិការសង្ស័យជូនបុគ្គលដែលទទួលបានការតែងតាំងត្រឹមត្រូវក្នុងបុគ្គលរាយការណ៍ ហើយត្រូវទទួលបានការណែនាំឱ្យយល់ដឹងពីអត្ថប្រយោជន៍នៃការមិនបង្ហាញព័ត៌មានប្រាប់អតិថិជន ។

- **និយោជិតជួរមុខ ៖**

  និយោជិតដែលទាក់ទងផ្ទាល់ជាមួយអតិថិជន ជាអ្នកទំនាក់ទំនងជាមួយអ្នកសម្អាតប្រាក់និងអ្នកផ្តល់ហិរញ្ញប្បទានភេរវកម្ម ដែលមានសក្តានុពល ត្រូវបណ្តុះបណ្តាលអំពីការសម្គាល់អត្តសញ្ញាណប្រតិបត្តិការសង្ស័យ និងវិធានការចាំបាច់ត្រូវអនុវត្តនៅពេលដែលប្រតិបត្តិការមួយមានលក្ខណៈគួរសង្ស័យ កត្តាដែលអាចនាំដល់ការសង្ស័យការរាយការណ៍ប្រតិបត្តិការដែលមានចំនួនសាច់ប្រាក់ច្រើន និងការពង្រឹងការយកចិត្តទុកដាក់ស្គាល់អតិថិជន ។

- **និយោជិត-ការបើកគណនី អតិថិជនថ្មី**

  និយោជិតដែលទទួលខុសត្រូវបើកគណនី ឬទទួលអតិថិជនថ្មី យ៉ាងហោចណាស់ត្រូវទទួល ការបណ្តុះបណ្តាលដូចគ្នានឹងនិយោជិតជួរមុខ ។ លើសពីនេះ និយោជិតគ្រប់រូបត្រូវ ទទួលបានការបណ្តុះបណ្តាល ពីការសម្គាល់អត្តសញ្ញាណ និងការផ្ទៀងផ្ទាត់អតិថិជន ការបើកគណនី ឬ ការបង្កើតទំនាក់ទំនងអាជីវកម្មជាមួយអតិថិជន ។

- **អ្នកត្រួតពិនិត្យនិងអ្នកគ្រប់គ្រង**

កម្រិតខ្ពស់បំផុតនៃការណែនាំ ដែលគ្របដណ្តប់ទិដ្ឋភាពនៃនីតិវិធីប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មត្រូវបានផ្តល់ទៅឱ្យអ្នកត្រួតពិនិត្យ និងអ្នកគ្រប់គ្រងដែលរួមមានការពិន័យចំពោះការមិនគោរពតាមកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់ និងនីតិវិធីប្រឆាំងហិរញ្ញប្បទានភេរវកម្ម ។

៣៦.៦ កម្មវិធីបង្កើនការយល់ដឹងនិងការបណ្តុះបណ្តាលទាំងនេះត្រូវធ្វើឡើងជាទៀងទាត់ ដោយផ្តល់វគ្គសិក្សាថ្មីៗដល់និយោជិត ។ និយោជិតថ្មីត្រូវបណ្តុះបណ្តាលក្នុងរយៈពេលបីខែមុនពេលចាប់ផ្តើមបំពេញ ការងារ ហើយចំពោះនិយោជិតជួរមុខ អ្នកត្រួតពិនិត្យនិងអ្នកគ្រប់គ្រងត្រូវផ្តល់វគ្គសិក្សាថ្មីៗប្រចាំឆ្នាំ ។

## ប្រការ៣៥.- សវនកម្មផ្ទៃក្នុង

៣៥.១ ក្រុមប្រឹក្សាភិបាលធានាថា សវនករផ្ទៃក្នុងត្រួតពិនិត្យមានប្រសិទ្ធភាព និងប្រតិបត្តិកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលមានក្នុងច្បាប់និងបទប្បញ្ញត្តិ និងប្រកាសនេះ ។

៣៥.២ ក្រុមប្រឹក្សាភិបាលត្រូវកំណត់ និងរៀបចំឯកសារឱ្យបានច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុងយ៉ាងហោចណាស់ត្រូវមាន ៖

- ការសាកល្បងប្រសិទ្ធភាពនៃគោលការណ៍ នីតិវិធី និងការត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ការធានាប្រសិទ្ធភាពនៃយន្តការត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម រួមមានការតែងតាំងមន្ត្រីប្រតិបត្តិ កម្មវិធីបង្កើនការយល់ដឹងនិងការបណ្តុះបណ្តាលបុគ្គលិក យន្តការពិនិត្យតាមដាននិយោជិត ក្បួនខ្នាតផ្ទៃក្នុងស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង
- ការធានាថា វិធានការបានបង្កើតស្របគ្នានឹងវិវឌ្ឍន៍ និងបម្រែបម្រួលបច្ចុប្បន្ននៃកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលជាប់ពាក់ព័ន្ធ ។

៣៥.៣ បុគ្គលរាយការណ៍ ត្រូវជូនដំណឹងមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអាជ្ញាធរអាណាព្យាបាលពីការតែងតាំង ឬការផ្លាស់ប្តូរសវនករផ្ទៃក្នុង និងវិធីសាស្ត្រនិងនីតិវិធី ដែលបានអនុវត្តដោយសវនករផ្ទៃក្នុង ។

៣៥.៤ សវនករផ្ទៃក្នុង ត្រូវផ្តល់ជូនជាលាយលក្ខណ៍អក្សរពីលទ្ធផលសវនកម្មទៅក្រុមប្រឹក្សាភិបាលឱ្យបានទៀងទាត់ ។ របាយការណ៍សវនកម្មប្រចាំឆ្នាំត្រូវបង្ហាញពីភាពមិនគ្រប់គ្រាន់នៃវិធានការ និងប្រព័ន្ធត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ ហើយក្រុមប្រឹក្សាភិបាលត្រូវចាត់វិធានការចាំបាច់ក្នុងការកែតម្រូវស្ថានការណ៍នេះ ។ បុគ្គលរាយការណ៍ត្រូវផ្តល់ជូនលទ្ធផលនិងរបាយការណ៍សវនកម្មមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាឱ្យបានទៀងទាត់ក្រោយពីបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

**ប្រការ ៣៦.-**

សមាជិកក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លេខាធិការដ្ឋានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងបុគ្គលរាយការណ៍ទាំងអស់ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ខែ ធ្នូ ឆ្នាំ ២០១០

**ទេសាភិបាល និងជា**

**ប្រធានក្រុមប្រឹក្សាភិបាល ស.ហ.ក**

ជា ចាន់តូ

**កន្លែងទទួល**
- ដូចប្រការ ៣៦ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងប្រៃសណីយ៍
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"